ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...២៨៧៤.......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ

អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ជាពិសេសអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៧១០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ អគ្គនាយកដ្ឋានពន្ធដារសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច បាននិងកំពុងចុះតាមគោលដៅសំខាន់ៗដើម្បីត្រួតពិនិត្យការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនឆ្នាំ២០១៦ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស សំដៅធានាបាននូវប្រសិទ្ធភាព សមភាព និងតម្លាភាពនៃការប្រមូលចំណូលពន្ធប្រភេទនេះ ដែលយុទ្ធនាការនេះបានផ្តើមធ្វើឡើងចាប់តាំងពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ រហូតមកដល់ពេលនេះ។

គិតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារ រួមជាមួយកម្លាំងសមត្ថកិច្ច បានធ្វើការផាកពិន័យនៅនឹងកន្លែងគោលដៅត្រួតពិនិត្យ និងបានរកឃើញថា ក្នុងក្របខ័ណ្ឌទូទាំងប្រទេស មានរថយន្តចំនួន **៤ ១១៨ គ្រឿង** ដែលមិនបានមកប្រកាសបង់ពន្ធបានទាន់ពេលវេលា ស្របតាមការកំណត់ដោយច្បាប់ ហើយរថយន្តទាំងនោះត្រូវបានតម្រូវឱ្យបង់ប្រាក់ពន្ធ រួមទាំងប្រាក់ពិន័យទោសទណ្ឌផងនៅនឹងកន្លែងត្រួតពិនិត្យតែម្តង ដោយប្រមូលប្រាក់ពន្ធសរុបបានចំនួន **៣ ៥៦៩ លានរៀល** (ប្រមាណជា **៨៩២ ៤០២,៥ ដុល្លារ**)។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជន ម្ចាស់រថយន្ត មេត្តាជ្រាបផងដែរថា ដោយសង្កេតឃើញថារថយន្តដែលមិនទាន់បានប្រកាសបង់ពន្ធ នៅតែធ្វើចរាចរនៅលើដងផ្លូវនៅឡើយ ដូច្នេះក្រុមការងារចម្រុះនៃអគ្គនាយកដ្ឋានពន្ធដារនៅតែបន្តយុទ្ធនាការចុះត្រួតពិនិត្យលើរថយន្តណាដែលមិនទាន់បង់ពន្ធប្រភេទនេះតទៅទៀត ដើម្បីឱ្យច្បាស់ថាយានយន្តទាំងអស់បានបំពេញកាតព្វកិច្ចបង់ពន្ធដោយស្មើភាពគ្នាតាមការកំណត់ដោយច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ម្ចាស់រថយន្តទាំងអស់មេត្តាជ្រាប និងចូលរួមអនុវត្តច្បាប់ប្រកបដោយស្មារតីសហការ និងការទទួលខុសត្រូវខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា
អគ្គនាយកដ្ឋាន ពន្ធដារ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អាគារកែងមហាវិថី សហព័ន្ធរុស្សី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh